# ការប្រជុំតំណាងក្រុមសន្សំប្រចាំខេត្តព្រៃវែង

នៅថ្ងៃទី ១៥ សីហា ២០០៨ នៅការិយាល័យសេដាកស្រុកបាភ្នំ ដែលមានទីតាំងនៅភូមិឈើកាច់ ឃុំឈើកាច់ ស្រុកបាភ្នំ ខេត្តព្រៃវែង (នៅខាងលិចឈាងខាងត្បូងផ្សារឈើកាច់) មានរៀបចំប្រជុំតំណាង ក្រុមសន្សំប្រចាំខេត្តព្រៃវែង ។ អ្នកចូលរួមសរុបចំនួន ១២៦ នាក់ ( ស្ត្រី ១៩ នាក់) មកពី ៥៣ ភូមិ ៤៧ ឃុំ ៨ ស្រុកនៅក្នុងខេត្តព្រៃវែង ដែលក្នុងនោះរួមមាន តំណាងក្រុមសន្សំ អជ្ញាធរមូលដ្ឋាន ( ភូមិ ឃុំ ស្រុក ៣ នាក់ ខេត្ត ៣ នាក់) គ្រូបង្រៀនចំនួន ៣ សាលា និងអ្នកពាក់ព័ន្ធផ្សេងៗចំនួន ៨ នាក់ មកពី ៤ ស្ថាប័ន ។ កិច្ចប្រជុំធ្វើឡើងក្នុងគោលបំណងដូចខាងក្រោមៈ

- ចែករំលែកបទពិសោធន៍ និងចំណេះដឹងផ្សេងៗ ក្នុងការគ្រប់គ្រងក្រុមឱ្យកាន់តែប្រសើរឡើងថែមទៀត
- បង្ហាញពីសមិទ្ធិផលដែលទទួលបានកន្លងមក គិតត្រឹមខែកក្កដា ឆ្នាំ២០០៨ និងទិសដៅរបស់កម្មវិធីសន្សំក្រោយឆ្នាំ ២០០៨
- ជំរុញកិច្ចសហការវាងអ្នកពាក់ព័ន្ធ ដើម្បីធ្វើឱ្យកម្មវិធីសន្សំ ក៏ដូចជាមូលដ្ឋានកាន់តែប្រសើរឡើង ថែមទៀត

ជាលទ្ធផលគិតរហូតមកដល់ត្រឹមចុងខែកក្កដា ២០០៨ នៅក្នុងខេត្តព្រៃវែងទាំងមូល គម្រោងសន្សំប្រាក់ ដើម្បីភាពអាស្រ័យលើខ្លួនឯងបានកំពុងគាំទ្រដល់ក្រុមសន្សំប្រាក់ចំនួន ៧៣៤ ក្រុម សមាជិកសរុប ១០១១៣ នាក់ ( ស្ត្រី ៥៣៤៩នាក់) ក្នុង ៣៩៤ ភូមិ ៥៧ឃុំ និង ៨ ស្រុក ដែលយើងអាចប្រមូល បានទុនសរុប ១០១៣ លានរៀល (២៥ ម៉ឺនដុល្លាអាមេរិក) ។ ក្រុមទាំងនេះត្រូវបានគាំទ្រដោយអ្នកសម្របសម្រួលក្រុមសន្សំប្រាក់តាមមូលដ្ឋាន (SGA) ចំនួន ៦១ នាក់ និងអ្នកសម្របសម្រួលក្រុមសន្សំប្រាក់ថ្នាក់ ភូមិចំនួន (VSA) ៣០៩ នាក់ ។

កម្មវិធីសន្សំ នឹងគ្រោងពង្រីកតំបន់គោលដៅរបស់ខ្លួនបន្ថែមទៀតនៅក្នុងខេត្តព្រៃវែង ក្នុងរយៈពេល ៣ ឆ្នាំខាងមុខ (២០០៨-២០១១) ។ នៅក្នុងខេត្តព្រៃវែងទាំងមូលនឹងមានក្រុមសន្សំសរុបចំនួន ២៥០០ ក្រុម សមាជិក ៣៧៥០០ នាក់ ( ស្ត្រី ៦០%) ៨៥០ភូមិ ១០០ឃុំ និង ១០ ស្រុក នៅខែ មិថុនា ២០១១ ។

ហើយសម្រាប់គម្រោងសន្សំប្រាក់ទាំងមូល យើងនឹងគ្រោងបង្កើតក្រុមសន្សំប្រាក់ឱ្យបាន ១០០០០ ក្រុម និង ១៦០.០០០ គ្រួសារ ៤០០០ ភូមិ ៥០០ ឃុំ ៩០ ស្រុក ១៦ ខេត្ត ទូទាំងប្រទេសកម្ពុជា ។

ឆ្លងតាមរយៈសិក្ខាសាលារយៈពេល ១ ថ្ងៃនេះ យើងសង្កេតឃើញថា អ្នកចូលរួមទាំងអស់មានការចាប់អារម្មណ៍ខ្លាំងលើការបង្កើតក្រុមសន្សំប្រាក់តាមរយៈការប្រមែប្រមូលធនធានពីខាងក្នុង ( ការសន្សំប្រាក់ដោយកសិករខ្លួនឯងផ្ទាល់) ជាពិសេសយើងទទួលបានការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់អាជ្ញាធរមូលដ្ឋាន ដែលបានគាំទ្រដល់កម្មវិធីនេះថា វាបានជួយដល់ការកាត់បន្ថយភាពក្រីក្រ និងការចូលរួមរបស់គ្រួសារកសិករក្រីក្រ ព្រមទាំងបានចូលរួមចំណែកក្នុងកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរបស់រាជរដ្ឋាភិបាល ។

ជារួមក្រុមសន្សំទាំងអស់គ្រោងនឹងពង្រីកការសន្សំរបស់គាត់ឱ្យកាន់តែច្រើនថែមទៀតក្នុងគោលបំណង កាត់បន្ថយការខ្ចីពីខាងក្រៅ ធ្វើឱ្យទុនវិលក្នុងភូមិរបស់គាត់ ។ ក្នុងនោះដែរ លោក **សៀង សុវណ្ណារ៉ា** ប្រធានសមាគមសន្សំប្រាក់ភូមិកណ្តាល ឃុំកំពង់សឹង ស្រុកព្រះស្តេច ខេត្តព្រៃវែង និយាយថា " សព្វថ្ងៃ ភូមិគាត់មានទុនសរុប ៤៨ លានរៀល សមាជិក ៦៦ នាក់ ហើយសម្រាប់ ៣ ឆ្នាំខាងមុខគាត់នឹង ប្រមូលទុនក្នុងភូមិរបស់គាត់តាមរយៈការសន្សំប្រាក់ដោយអាស្រ័យខ្លួនឯងឱ្យបាន ២៥០ លានរៀល , សមាជិក ២០០ គ្រួសារ ហើយក្នុងនោះ ១០០គ្រួសារជាអ្នកក្រីក្រ ។